# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាងនាមប្រជារាស្ត្រខ្មែរ

**សំណុំរឿងសភាព្រហ្មទណ្ឌ**

លេខ : ៩៦

ចុះថ្ងៃទី ៧-២-២០០៦

**សាលដីកា**

លេខ : ១២៣ "ជ"

ចុះថ្ងៃទី ២៥-១១-២០០៨

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ៨-២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍នាថ្ងៃទី ២៥-១១-២០០៨ ដោយមានសមាសភាពដូចខាងក្រោម :

**<u>សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ</u>**

| | | |
|---|---|---|
| លោក | [redacted] | ជាប្រធាន |
| លោក | [redacted] | ជាចៅក្រមប្រឹក្សា |
| លោក | [redacted] | ជាចៅក្រមប្រឹក្សា |

**<u>តំណាងមហាអយ្យការ</u>**

| | | |
|---|---|---|
| លោក | [redacted] | ជាព្រះរាជអាជ្ញា |

**<u>ក្រឡាបញ្ជី</u>**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងព្រហ្មទណ្ឌលេខ៩៦ ចុះថ្ងៃ ៧-២-២០០៦ រវាង :

១-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ២៣ឆ្នាំ កើតនៅបាភ្នំ ខេត្តព្រៃវែង ទីលំនៅ [redacted] ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូន២នាក់ ។

-ចាប់ខ្លួន ១៩-៩-២០០៣ ឃុំខ្លួនថ្ងៃទី ២៣-៩-២០០៣ ។

២-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករសំណង់ កើតនៅស្រុកបាភ្នំ ខេត្តព្រៃវែង ទីលំនៅ[redacted] ខណ្ឌមានជ័យ ក្រុងភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" ។

-ចាប់ខ្លួន ១៩-៩-២០០៣ ឃុំខ្លួន ២៣-៩-២០០៣ ។

<u>ជាប់ចោទពីបទ</u> : **ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់** ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៩-៩-២០០៣ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] យឹម ភេទស្រី អាយុ៤៣ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នផ្ទះលេខ២២ ក្រុម៩ សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ។

-ជនរងគ្រោះឈ្មោះ [redacted] សារឿន ជាប្តីរបស់ដើមបណ្តឹង ។

I-**អំពីអង្គហេតុ**

តាមពាក្យបណ្តឹងចុះថ្ងៃទី ១៩-៩-២០០៣ របស់ឈ្មោះ [redacted] យឹម បានប្តឹងពី ចោរប្លន់ម៉ូតូម៉ាក C100កូរ៉េ ពណ៌ក្រហម គ្មានស្លាកលេខ,លេខតួC9020084 ,លេខម៉ាកស៊ីន CT100E 1919788 កាលពីថ្ងៃទី ១៩-៩-២០០៣ វេលាម៉ោង២៣h១៥ ពួកវាមានគ្នា២នាក់ បានប្លន់ម៉ូតូពីប្តីខ្លួនឈ្មោះ [redacted] ភី (ហៅ [redacted] សារឿន)ត្រង់ចំណុចមុខផ្ទះ៣៥C ក្រុម៥៤ ផ្លូវ៣៥០ សង្កាត់បឹងកេងកងទី៣ ខ័ណ្ឌចំការមន បណ្តាលអោយរបួសចំនួន២កន្លែង គឺត្រង់ចុងដោះខាងឆ្វេងចំនួន១គ្រាប់ បៀមគ្រាប់ខាងក្នុង និងមួយគ្រាប់ទៀតត្រូវត្រង់ស្មាខាងស្តាំ បៀមគ្រាប់ខាងក្នុង ។

-បានឃើញ : សាលក្រមព្រហ្មទណ្ឌលេខ ២៦ "ឃ" ចុះថ្ងៃទី ២២-៤-២០០៤ របស់សាលាដំបូងក្រុងភ្នំពេញ បានសម្រេចសេចក្តីដូចខាងក្រោម :

១-ផ្តន្ទាទោសឈ្មោះ [redacted] ណៃ ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ មានទីលំនៅមណ្ឌលកុមារសង្កាត់ជ្រោយចង្វារ ខ័ណ្ឌឫស្សីកែវ ក្រុងភ្នំពេញ និងឈ្មោះ [redacted] រិនដា ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ មានទីលំនៅភូមិឃ្លាត សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ ដាក់ពន្ធនាគារចំនួន៨(ប្រាំបី)ឆ្នាំ គិតបន្តពីការអនុវត្តសាលក្រមលេខ ២៥ "ឃ" ចុះថ្ងៃទី ២២ ខែមេសា ឆ្នាំ២០០៤ របស់ចៅក្រមជំនុំជម្រះតុលាការក្រុងភ្នំពេញ ចប់សព្វគ្រប់តាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២-បង្គាប់ឱ្យ [redacted] ណៃ និង [redacted] រិនដា សងថ្លៃថ្នាំព្យាបាលចំនួន ៣០០០ដុល្លា(បីពាន់)ឱ្យទៅជនរងគ្រោះឈ្មោះ [redacted] សារឿន គិតចាប់ពីសាលក្រមចូលជាស្ថាពរ ។ ក្នុងករណីទណ្ឌិតខាងលើរឹងរូសពុំព្រមសងត្រូវដាក់គុកបង្ខំ ដល់រូបកាយម្នាក់ៗ តាមមាត្រា៧,៨និង៩ នៃច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៣-រឹបអូសអាវុធខ្លីម៉ាកK59 ក្រូមេ រឹបអូសទុកជាសម្បត្តិរដ្ឋ ។

៤-សំបកកាទូសគ្រាប់K59 ចំនួន៤សំបក និងក្បាលគ្រាប់ចំនួន១ រឹបអូសបំផ្លាញចោល ។

៥-សាលក្រមនេះ ជំនុំជម្រះនិងប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ ជនជាប់ចោទ មេធាវីការពារជនជាប់ចោទ ជនរងគ្រោះ បើកផ្លូវប្តឹងទាស់និងឧទ្ធរណ៍ ក្នុងកំណត់ច្បាប់ ។

សាលក្រមនេះ ត្រូវបានឈ្មោះ [redacted] រិនដា និងឈ្មោះ [redacted] ណៃ ប្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៩-៥-២០០៤ ត្រង់ចំណុចសាលក្រមទាំងមូល ។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] ណៃ (អវត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] រិនដា (អវត្តមាន)

ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានរបាយការណ៍សង្ខេបរឿង

**សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ :**

-ក្រោយពីបានពិនិត្យ លើសំណុំរឿងយល់ឃើញថា មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ លើជនជាប់ចោទ ។ តំណាងមហាអយ្យការសូមតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៦ "ឃ" ចុះថ្ងៃទី ២២-៤-២០០៤ របស់សាលាដំបូងក្រុងភ្នំពេញ ទុកជាបានការដដែល ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ។

-ក្រោយពីបានស្តាប់អំនានចម្លើយរបស់ជនជាប់ចោទ ។

-ក្រោយពីបានស្តាប់អំនានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

-ក្រោយពីបានពិនិត្យភស្តុតាងឯកសារនានា ។

-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## សាលាឧទ្ធរណ៍

## យល់ឃើញថា :

-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃ ១៩ ខែឧសភា ឆ្នាំ២០០៤ របស់ជនជាប់ចោទ [redacted] វិនដា និង [redacted] ណៃ ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមបញ្ញត្តិមាត្រា ១៧៨ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន ។

-សាលាឧទ្ធរណ៍បានសុំមេធាវីរួចហើយ តាមលិខិតលេខ ៣០២ ចុះថ្ងៃ ២៣-១០-២០០៨ តែគ្មានចម្លើយតប ហើយជនជាប់ចោទក៏មិនបានឱ្យដំណឹង ។ ម្យ៉ាងទៀតទណ្ឌកម្មលើជនជាប់ចោទស្រាលទៅហើយ ពុំគប្បីរង់ចាំមេធាវីទេ ។

-ជាបទល្មើសជាក់ស្តែង ដែលសមត្ថកិច្ចចាប់បានជនល្មើស នៅពេលដែលកំពុងប្រព្រឹត្តបទល្មើសប្លន់ម៉ូតូកាលពីថ្ងៃ ១៩-៩-២០០៣ នៅសង្កាត់បឹងកេងកង៣ ក្រុងភ្នំពេញ ។

-ជនជាប់ចោទឈ្មោះ [redacted] ណៃ បានបាញ់ម្ចាស់ម៉ូតូ៤គ្រាប់ ត្រូវ២គ្រាប់ ក្នុងបំណងសម្លាប់ ដើម្បីប្លន់នោះគឺជាបទ ឃាដកម្មគិតទុកជាមុន ដែលត្រូវផ្តន្ទាទោសតាមមាត្រា៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ តែដោយគ្មានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា សាលាឧទ្ធរណ៍ពុំអាចកែប្រែបទចោទបានឡើយ ។

-សាលក្រមព្រហ្មទណ្ឌលេខ ២៦ "ឃ" ចុះថ្ងៃ ២២-៤-២០០៤ របស់សាលាដំបូងក្រុងភ្នំពេញ មានលក្ខណៈត្រឹមត្រូវគួរតម្កល់ទុក ។

## ហេតុដូច្នេះ

## ១និច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃ ១៩ ខែឧសភា ឆ្នាំ២០០៤ របស់ជនជាប់ចោទ [redacted] វិនដា និង [redacted] ណៃ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែលើកចោលដោយទាស់គតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៦ "ឃ" ចុះថ្ងៃ ២២-៤-២០០៤ របស់សាលាដំបូងក្រុងភ្នំពេញ ទុកជាបានការ ។

៣-បន្តឃុំខ្លួនជនជាប់ចោទ [redacted] ណៃ [redacted] វិនដា ។

លុបចោលវិធានអនុវត្តដាក់គុកបង្ខំរូបកាយទារធនទណ្ឌចេញពីការប្រកាសសាលក្រម តាមមាត្រា ៥២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៤-សាលដីកានេះ ជំនុំជម្រះនិងប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី

-បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុក អនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែងនិងកងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះ អោយបានសម្រេចប្រសិនបើមានសំណូមពរ ត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| លេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

---

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ,ថ្ងៃទី.... ខែ.... ឆ្នាំ២០១....
ក្រឡាបញ្ជី